កក្កដា ២០១៦

# ព័ត៌មានអំពីភាគហ៊ុន

## ភាគហ៊ុនដែលចុះបញ្ជីនៅផ្សារមូលបត្រកម្ពុជា

រដ្ឋាករទឹកស្វយ័ត
ក្រុងភ្នំពេញ

PWSA



ហ្គ្រេនធ្វីន អ៊ិនធើណេសិនណល
(ខេមបូឌា) ភីអិលស៊ី

GTI





PPAP

កំពង់ផែស្វយ័ត
ភ្នំពេញ



PPSP

ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី

ផ្សារមូលបត្រកម្ពុជា
CSX

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
អគារលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក
ខណ្ឌដូនពេញ រាជធានីភ្នំពេញ
០២៣ ៧២៤ ០៤៦ | www.ppwsa.com.kh

## សេចក្តីសង្ខេបអំពីក្រុមហ៊ុន

**បង្កើតឡើងឆ្នាំ៖១៨៩៥ ចំនួនបុគ្គលិក៖ ៨៥១ នាក់**



ឯកឧត្តម ស៊ឹម ស៊ីថា
អគ្គនាយក

> រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ក) ត្រូវបានបង្កើតឡើងក្នុងទម្រង់ជាគ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ចស្ថិតក្រោមច្បាប់ស្តីពីសហគ្រាសសាធារណៈ។ នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ រ.ទ.ស.ក បានចុះបញ្ជីជាផ្លូវការនៅផ្សារមូលបត្រកម្ពុជា ដោយបានបោះផ្សាយលក់ភាគហ៊ុនធម្មតាចំនួន ១៣.០៤៥.៩៧៥ ភាគហ៊ុន ដែលស្មើនឹង១៥%នៃចំនួនភាគហ៊ុនធម្មតាសរុប។

> រ.ទ.ស.ក. បានប្តេជ្ញាចិត្តបន្តធ្វើឲ្យសេវាផ្គត់ផ្គង់ទឹកស្អាតរបស់ខ្លួនមានការរីកចម្រើនប្រកបដោយចេរភាព ព្រមទាំងធ្វើជាអ្នកប្រឹក្សាជាអ្នកសម្របសម្រួល ដើម្បីឲ្យប្រជាពលរដ្ឋនៅក្នុងទីក្រុងនិងបណ្តាខេត្តផ្សេងទៀតក្នុងប្រទេសកម្ពុជាទទួលបានទឹកស្អាតប្រើប្រាស់។ រ.ទ.ស.ក. ក៏បានប្តេជ្ញាចិត្ត ជួយដល់ប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀតក្នុងការផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាពលរដ្ឋរបស់ពួកគេផងដែរ។

> បេសកកម្មរបស់រ.ទ.ស.ក.គឺធានាឱ្យបាននូវការផ្គត់ផ្គង់ទឹកស្អាតគ្មានមេរោគ ២៤ ម៉ោងក្នុងមួយថ្ងៃ និង ៧ ថ្ងៃក្នុងមួយសប្តាហ៍ មានសម្ពាធគ្រប់គ្រាន់ និងក្នុងតម្លៃសមស្រប ជូនប្រជាពលរដ្ឋទូទាំងរាជធានីភ្នំពេញ និងទីប្រជុំជនរបស់ខេត្តកណ្តាលដែលជាប់នឹងរាជធានីភ្នំពេញ ដោយមិនមើលរំលងប្រជាពលរដ្ឋក្រីក្រឡើយ។ ក្រៅពីនេះ រ.ទ.ស.ក. បាននិងកំពុងចែករំលែកនូវបទពិសោធន៍របស់ខ្លួនដល់បណ្តារដ្ឋាករទឹកខេត្តក្រុងមួយចំនួននៅក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងបណ្តាអង្គភាពទឹកស្អាតក្នុងតំបន់ និងក្នុងពិភពលោក។

> រ.ទ.ស.ក. បានបូមទឹកពីទន្លេសាប ទន្លេបាសាក់ ទន្លេមេគង្គលើ និងទន្លេមេគង្គក្រោម ទៅចម្រោះនិងផលិតជាទឹកស្អាតនៅរោងចក្រផលិតទឹកស្អាតភូមិព្រែកចំការមន ជ្រោយចង្វារ និងនិរោធ។

## ព័ត៌មានអំពីអាជីវកម្ម

> នៅក្នុងឆ្នាំ ២០១៤ រ.ទ.ស.ក. បានផលិតទឹកស្អាតចំនួន ១៤៩.៥៥២.០៩៥ ម៉ែត្រគូប ដោយគោរពតាមស្តង់ដាររបស់អង្គការសុខភាពពិភពលោក ហើយបានដាក់បណ្តាញចែកចាយទឹកទៅកាន់អតិថិជនរបស់ខ្លួនចំនួន ១៨.៤៩៧ បណ្តាញ។ នៅចុងឆ្នាំ ២០១៤ នេះ រ.ទ.ស.ក. មានបណ្តាញចែកចាយសរុបចំនួន ២.៣១២គីឡូម៉ែត្រ សម្រាប់ការផ្គត់ផ្គង់បណ្តាញចែកចាយបន្តចំនួន ២៧០.៨១២ នៅរាជធានីភ្នំពេញ។

> នៅក្នុងឆ្នាំ ២០១៤ រ.ទ.ស.ក.ទទួលបានពានរង្វាន់ចំនួន ៦ ដូចខាងក្រោម:

- ពានរង្វាន់ Best Quality Leadership Award - ខែធ្នូ ២០១៤
- ពានរង្វាន់ The Bizz Arabic Award 2014 - ខែកញ្ញា ២០១៤
- ពានរង្វាន់ International Trophy For Quality - ខែមិនា ២០១៤
- ពានរង្វាន់ International Europe Award For Quality - ខែតុលា ២០១៤
- ពានរង្វាន់ European Award for Best Practices - ខែមិថុនា ២០១៤
- ពានរង្វាន់ Diamond Eye Award For Quality And Excellence - ខែកញ្ញា២០១៤

## គោលនយោបាយភាគលាភ៖

ប្រសិនបើមានប្រាក់ចំណេញ ក្រុមប្រឹក្សាភិបាលនៃរ.ទ.ស.ក. អាចសម្រេចផ្ទេរទឹកប្រាក់ទាំងនោះសម្រាប់៖

១. ការទូទាត់ការខាតបង់នៅក្នុងឆ្នាំកន្លងទៅ

២. បន្ទាប់ពីបានទូទាត់ការខាតបង់នៅក្នុងឆ្នាំកន្លងទៅរួច ប្រសិនបើនៅមានប្រាក់ចំណេញ នោះប្រាក់ចំណេញនេះត្រូវបែងចែកសម្រាប់៖

ក. ផ្តល់ជាប្រាក់បំណាច់ដល់ថ្នាក់ដឹកនាំ និងនិយោជិតដូចខាងក្រោម៖

- ក្នុងករណីប្រាក់ចំណេញនៅសល់មានចំនួនពី ៥% ដល់ ១០% នៃចំណាយដំណើរការរបស់រ.ទ.ស.ក. សរុបក្នុងឆ្នាំ នោះប្រាក់បំណាច់ត្រូវស្មើនឹងមួយខែនៃប្រាក់បៀវត្សសុទ្ធរបស់ថ្នាក់ដឹកនាំ និងនិយោជិតនីមួយៗ
- ក្នុងករណីប្រាក់ចំណេញមានចំនួនពី ១០% ដល់ ២០% នៃចំណាយដំណើរការរបស់រ.ទ.ស.ក. សរុបក្នុងឆ្នាំ នោះប្រាក់បំណាច់ត្រូវស្មើនឹងពីរខែនៃប្រាក់បៀវត្សសុទ្ធរបស់ថ្នាក់ដឹកនាំ និងនិយោជិតនីមួយៗ
- ក្នុងករណីប្រាក់ចំណេញលើសពី២០% នៃចំណាយដំណើរការរបស់រ.ទ.ស.ក. សរុបក្នុងឆ្នាំ នោះប្រាក់បំណាច់ត្រូវស្មើនឹងបីខែនៃប្រាក់បៀវត្សសុទ្ធរបស់ថ្នាក់ដឹកនាំ និងនិយោជិតនីមួយៗ

ខ. ចំនួន២%សម្រាប់ប្រាក់សោធននិវត្តន៍និងអសមត្ថភាពវិជ្ជាជីវៈ

គ. បង្កើតភាគបម្រុងតាមច្បាប់ ៥%

ឃ. បង្កើតភាគបម្រុងសេរី៥%

ង. មូលនិធិ៥% លើប្រាក់ចំណេញសម្រាប់បម្រើផលប្រយោជន៍សង្គម ដែលត្រូវកត់ត្រាចូលក្នុងបន្ទុកក្នុងឆ្នាំដែលធ្វើប្រតិបត្តិការចំណាយនោះ។

៣. ចំនួនទឹកប្រាក់ដែលនៅសល់បន្ទាប់ពីការបែកចែកខាងលើនេះត្រូវ៖

ក. ដកប្រាក់រក្សាទុកដើម្បីធ្វើការវិនិយោគនាពេលខាងមុខ ដែលចំនួននេះត្រូវអនុម័តដោយក្រុមប្រឹក្សាភិបាល

ខ. ប្រាក់នៅសល់ពីការរក្សាទុកសម្រាប់វិនិយោគនេះត្រូវធ្វើការបែងចែក ៨៥% ទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិង ១៥%ទៅភាគហ៊ុនិកដែលជាវិនិយោគិនសាធារណៈ។

| ទិន្នន័យផ្សារហ៊ុន | 2013 | 2014 | 2015 |
|---|---|---|---|
| មូលធនូបនីយកម្មទីផ្សារ(លានរៀល) | 466,176 | 382,682 | 441,824 |
| ថ្លៃចុងក្រោយ | 5,360 | 4,400 | 5,080 |
| ថ្លៃខ្ពស់ | 6,700 | 5,120 | 6,400 |
| ថ្លៃទាប | 4,600 | 4,220 | 4,000 |
| តម្លៃជួញដូរ/ថ្ងៃ(លានរៀល) | 59 | 17 | 17 |
| អនុបាតជុំបង្វិល[១] | 19.01% | 6.79% | 6.90% |
| **ការវាយតម្លៃ** | | | |
| ថ្លៃ/ចំណេញ[២] | 13.64 | 10.66 | 9.89 |
| ថ្លៃ/តម្លៃក្នុងបញ្ជី[៣] | 1.53 | 1.11 | 1.12 |
| ទិន្នផលភាគលាភ | 1.02% | 2.39% | 3.00% |
| អនុបាតភាគលាភបានបង់ | 12.50% | 20.00% | 23.30% |
| ភាគលាភជាសាច់ប្រាក់ក្នុងមួយភាគហ៊ុន | 54.74 | 105.20 | 152.57 |
| **សូចនាករហិរញ្ញវត្ថុសំខាន់ផ្សេងទៀត** | | | |
| អនុបាតចំណេញធៀបនឹងមូលធន | 5.62% | 6.39% | 7.49% |
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម | 3.63% | 4.04% | 4.73% |
| អនុបាតទ្រព្យសកម្មធៀបនឹងមូលធន | 1.58 | 1.58 | 1.58 |
| អនុបាតចរន្ត | 4.47 | 5.41 | 5.06 |
| **ព័ត៌មានអំពីការលក់ភាគហ៊ុនលើកដំបូង IPO** | | | |
| ថ្លៃ IPO | | | 6,300 |
| តម្លៃចារឹក | | | 1,000 |
| ចំនួនភាគហ៊ុនចុះបញ្ជី | | | 86,973,162 |
| ចំនួនភាគហ៊ុនបោះផ្សាយ | | | 13,045,975 |
| កាលបរិច្ឆេទជួញដូរដំបូង | | | ១៨ មេសា ២០១២ |
| ថ្លៃបិទដំបូង | | | 9,300 |
| ▪ **ក្រុមហ៊ុនធានាទិញមូលបត្រ:** | គុងយ៉ាង ស៊ីយូរីធី (ខេមបូឌា) ភីអិលស៊ី | | |
| **ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនចំនួនច្រើន[៤]** | | | % |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | | 85.00 |

| របាយការណ៍ហិរញ្ញវត្ថុ | | | (លានរៀល) |
|---|---|---|---|
| **តារាងតុល្យការ** | **2013** | **2014** | **2015** |
| ទ្រព្យសកម្ម | 1,098,976.72 | 1,166,051.07 | 1,240,120.08 |
| ▪ ទ្រព្យសម្បត្តិ,រោងចក្រនិងបរិក្ខារ | 835,552.69 | 874,742.67 | 936,711.94 |
| ▪ ទ្រព្យសកម្មរយៈពេលខ្លី | 252,538.36 | 287,958.25 | 300,765.57 |
| ▪ សន្និធិ | 35,083.36 | 40,501.86 | 53,718.24 |
| ▪ គណនីត្រូវទទួល | 29,771.08 | 30,624.91 | 34,315.10 |
| ▪ សាច់ប្រាក់ | 10,568.72 | 14,962.14 | 12,555.44 |
| មូលធនរបស់ភាគហ៊ុនិក | 695,181.63 | 736,168.63 | 783,968.18 |
| ▪ ដើមទុន | 541,227.28 | 541,227.28 | 541,227.28 |
| ▪ ចំណេញរក្សាទុក | 38,088.03 | 45,747.91 | 56,949.13 |
| បំណុល | 403,795.09 | 429,882.45 | 456,151.89 |
| ▪ បំណុលរយៈពេលខ្លី | 56,551.73 | 53,256.51 | 59,497.70 |
| ▪ គណនីត្រូវបង់ | 29,859.91 | 21,509.97 | 27,308.00 |
| **របាយការណ៍ចំណេញខាត** | | | |
| ចំណូល | 151,580.21 | 156,542.85 | 191,348.25 |
| ចំណេញដុល | - | - | - |
| ចំណេញមុនបង់ពន្ធ | 51,532.93 | 44,651.58 | 54,642.64 |
| ចំណេញសុទ្ធ | 38,088.03 | 45,747.91 | 56,949.13 |
| ចំណេញក្នុងមួយភាគហ៊ុន(រៀល) | 437.93 | 526.00 | 654.79 |
| **របាយការណ៍លំហូរសាច់ប្រាក់** | | | |
| លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ | 74,840.50 | 84,204.48 | 78,919.84 |
| លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ | (112,044.95) | (101,087.81) | (81,663.02) |
| លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន | 33,797.13 | 21,276.75 | 336.47 |
| សាច់ប្រាក់សុទ្ធ | (3,407.32) | 4,393.43 | (2,406.71) |
| ▪ **ក្រុមហ៊ុនសវនកម្ម :** | PricewaterhouseCoopers (Cambodia) Ltd. | | |

| ក្រុមប្រឹក្សាភិបាល | មុខតំណែង |
|---|---|
| ១. ឯកឧត្តម ស៊ឹម ណារ៉ា | ប្រធានក្រុមប្រឹក្សាភិបាល(តំណាងក្រសួងឧស្សាហកម្មនិងសិប្បកម្ម) |
| ២. ឯកឧត្តម ស៊ឹម ស៊ីថា | សមាជិកក្រុមប្រឹក្សាភិបាល(អគ្គនាយក រ.ទ.ស.ភ) |
| ៣. ឯកឧត្តម ម៉ី វ៉ាន់ | សមាជិកក្រុមប្រឹក្សាភិបាល(តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) |
| ៤. ឯកឧត្តម ឃួង ស្រេង | សមាជិកក្រុមប្រឹក្សាភិបាល(តំណាងសាលារាជធានីភ្នំពេញ) |
| ៥. លោកស្រី ងិន ចន្ទ្រា | សមាជិកក្រុមប្រឹក្សាភិបាល(តំណាងបុគ្គលិក រ.ទ.ស.ភ) |
| ៦. លោក ចាង យុនហ្វេង | សមាជិកក្រុមប្រឹក្សាភិបាល(អភិបាលមិនមែនប្រតិបត្តិ តំណាងភាគហ៊ុនិកឯកជន) |
| ៧. លោក អោម សេងបូរ៉ា | សមាជិកក្រុមប្រឹក្សាភិបាល(អភិបាលឯករាជ្យ) |



ហ្គ្រេនធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី
ភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅ
ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
០២៣ ៨៩០ ៣២៥ | www.grandtwins.com.kh

## សេចក្តីសង្ខេបអំពីក្រុមហ៊ុន

បង្កើតឡើងឆ្នាំៈ២០០៧ ចំនួនបុគ្គលិកៈ ៥,២១៣ នាក់



លោក ឡៅ ឈុងតេ
នាយកប្រតិបត្តិ

ក្រុមហ៊ុន ហ្គ្រេនធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី គឺជាក្រុមហ៊ុនផលិតសម្លៀកបំពាក់ដែលបានបង្កើតឡើងក្នុងឆ្នាំ២០០៧។ នៅឆ្នាំ២០០៨ ក្រុមហ៊ុន ហ្គ្រេនធ្វីន បានទិញយកក្រុមហ៊ុនQMI Industrial Co., Ltd ដែលជារោងចក្រកាត់ដេរដ៏ធំមួយក្នុងចំណោមរោងចក្រកាត់ដេរធំៗដំបូងបង្អស់ដែលបានធ្វើអាជីវកម្មនៅក្នុងប្រទេសកម្ពុជាក្នុងកំឡុងទសវត្សរ៍ឆ្នាំ១៩៩០។ ក្រុមហ៊ុន ហ្គ្រេនធ្វីន គឺជារោងចក្រម៉ៅការបន្ត និងជារោងចក្រផលិតសម្លៀកបំពាក់ផ្ទាល់សម្រាប់នាំចេញ។ សព្វថ្ងៃ ផលិតផលរបស់ក្រុមហ៊ុន ហ្គ្រេនធ្វីន រួមមានម៉ាកសម្លៀកបំពាក់កីឡាល្បីៗដូចជាម៉ាក Adidas, Reebok, Taylor Made, Salomon, New Balance (NB), Kohl's, Nautica, North Face, Russell Athletic។ល។ គោលដៅនាំចេញរបស់ក្រុមហ៊ុន ហ្គ្រេនធ្វីន មានដូចជាបណ្តាប្រទេសក្នុងតំបន់អឺរ៉ុប(៦៣%នៃប្រាក់ចំណូលសរុបក្នុងឆ្នាំ២០១៥) សហរដ្ឋអាមេរិក(១៧%នៃប្រាក់ចំណូលសរុបក្នុងឆ្នាំ២០១៥) តំបន់អាស៊ីនិងបណ្តាប្រទេសដទៃទៀត(២០%នៃប្រាក់ចំណូលសរុបក្នុងឆ្នាំ២០១៥)។

## ព័ត៌មានអំពីអាជីវកម្ម

> ក្រុមហ៊ុន ហ្គ្រេនធ្វីន ទទួលបានការលើកលែងពន្ធពីប្រទេសកាណាដានិងសហភាពអឺរ៉ុប
> បច្ចុប្បន្ននេះក្រុមហ៊ុន ហ្គ្រេនធ្វីន ស្ថិតនៅលើផ្ទៃដីទំហំ ៣២.៣៤១ ម៉ែត្រការ៉េ ក្នុងប្រទេសកម្ពុជា ជាមួយនឹងរោងចក្រទំហំ១១.៦៨២ម៉ែត្រការ៉េ
> ក្រុមហ៊ុន ហ្គ្រេនធ្វីន មានគម្រោងប្រើប្រាស់ប្រាក់២៦.០០០លានរៀលដែលបានមកពីការលក់ភាគហ៊ុនដើម្បីពង្រីករោងចក្របន្ថែមជាពិសេសគឺដើម្បីបញ្ចប់ការសាងសង់ខ្សែសង្វាក់ផលិតកម្មថ្មីចំនួនពីរ
> ចំនួល៨០%របស់ក្រុមហ៊ុនគឺបានមកពីក្រុមហ៊ុនAdidas

## គោលនយោបាយភាគលាភ

ប្រាក់ចំណេញដែលនៅសល់ពីការបែងចែកខាងក្រោមនេះ នឹងត្រូវបានផ្តល់ឲ្យទាំងស្រុងឬមួយផ្នែកដល់ភាគហ៊ុនិកធម្មតាៈ

១) ១០% នៃប្រាក់ចំណេញដែលនៅសល់ បន្ទាប់ពីទូទាត់ការខាតបង់កាលពីឆ្នាំកន្លងទៅ នឹងត្រូវទុកជាប្រាក់បម្រុងសម្រាប់ការខាតបង់នាពេលអនាគត

២) បន្ទាប់ពីទូទាត់ការខាតបង់កាលពីឆ្នាំមុន និងការដកប្រាក់សម្រាប់ទុកបម្រុង ប្រាក់ចំណេញដែលនៅសល់នឹងត្រូវបានបែងចែកដូចខាងក្រោមៈ

ក) មិនលើសពី ៣%នៃប្រាក់ចំណេញសរុបក្រោយពេលបង់ពន្ធនឹងត្រូវបែងចែកជាប្រាក់បំណាច់សម្រាប់ក្រុមប្រឹក្សាភិបាល

ខ) មិនតិចជាង ៥%នៃប្រាក់ចំណេញសរុបក្រោយពេលបង់ពន្ធនឹងត្រូវបានបែងចែកជូនទៅដល់និយោជិតជាប្រាក់រង្វាន់

| ទិន្នន័យជួញដូរ | 2013 | 2014 | 2015 |
|---|---|---|---|
| មូលធនូបនីយកម្មទីផ្សារ(លានរៀល) | - | 276,000 | 160,800 |
| ថ្លៃចុងក្រោយ | - | 6,900 | 4,020 |
| ថ្លៃខ្ពស់ | - | 9,640 | 7,180 |
| ថ្លៃទាប | - | 6,900 | 4,000 |
| តម្លៃជួញដូរ/ថ្ងៃ(លានរៀល) | - | 68.18 | 10.09 |
| អនុបាតជុំបង្វិល[១] | - | 5.67% | 2.69% |
| **ការវាយតម្លៃ** | | | |
| ថ្លៃ/ចំណេញ[២] | - | 9.08 | 14.37 |
| ថ្លៃ/តម្លៃក្នុងបញ្ជី[៣] | - | 1.06 | 0.63 |
| ទិន្នផលភាគលាភ | - | 2.57% | 1.34% |
| អនុបាតភាគលាភបានបង់ | - | 45.49% | 49.99% |
| ភាគលាភជាសាច់ប្រាក់ក្នុងមួយភាគហ៊ុន | - | 177 | 54 |
| **សូចនាករហិរញ្ញវត្ថុសំខាន់ផ្សេងទៀត** | | | |
| អនុបាតចំណេញធៀបនឹងមូលធន | 19.46% | 6.66% | 1.67% |
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម | 16.72% | 5.88% | 1.45% |
| អនុបាតទ្រព្យសកម្មធៀបនឹងមូលធន | 1.16 | 1.11 | 1.19 |
| អនុបាតចរន្ត | 6.15 | 8.50 | 5.28 |
| **ព័ត៌មានអំពីការលក់ភាគហ៊ុនលើកដំបូង IPO** | | | |
| ថ្លៃ IPO | | | 9,640 |
| តម្លៃចារឹក | | | 1,000 |
| ចំនួនភាគហ៊ុនចុះបញ្ជី | | | 40,000,000 |
| ចំនួនភាគហ៊ុនបោះផ្សាយ | | | 8,000,000 |
| កាលបរិច្ឆេទជួញដូរដំបូង | | | ១៦ មិថុនា ២០១៤ |
| ថ្លៃបិទដំបូង | | | 9,220 |
| ▪ **ក្រុមហ៊ុនធានាទិញមូលបត្រ:** | ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី | | |

| ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនចំនួនច្រើន[៤] | % |
|---|---|
| ១. ក្រុមហ៊ុន ហ្រ្គេនធ្វីន អ៊ីនធើណេសិនណល | 41.00 |
| ២. HOPE RIDGE LIMITED | 9.60 |

| របាយការណ៍ហិរញ្ញវត្ថុ | | | (លានរៀល) |
|---|---|---|---|
| **តារាងតុល្យការ** | 2013 | 2014 | 2015 |
| ទ្រព្យសកម្ម | 191,272.68 | 289,976.82 | 304,850.95 |
| ▪ ទ្រព្យសម្បត្តិ,រោងចក្រនិងបរិក្ខារ | 24,943.05 | 37,139.97 | 46,973.35 |
| ▪ ទ្រព្យសកម្មរយៈពេលខ្លី | 165,786.93 | 252,095.72 | 257,837.71 |
| ▪ សន្និធិ | 29,368.69 | 34,226.47 | 36,405.75 |
| ▪ គណនីត្រូវទទួល | 134,705.06 | 194,287.46 | 216,326.16 |
| ▪ សាច់ប្រាក់ | 1,713.18 | 23,581.79 | 5,105.80 |
| មូលធនរបស់ភាគហ៊ុនិក | 164,328.94 | 260,333.14 | 256,034.75 |
| ▪ ដើមទុន | 31,960.00 | 40,750.00 | 40,500.00 |
| ▪ ចំណេញរក្សាទុក | 132,368.94 | 149,167.14 | 145,550.75 |
| បំណុល | 26,943.74 | 29,643.69 | 48,816.20 |
| ▪ បំណុលរយៈពេលខ្លី | 26,943.74 | 29,643.69 | 48,815.24 |
| ▪ គណនីត្រូវបង់ | 8,302.66 | 8,415.56 | 15,116.07 |
| **របាយការណ៍ចំណេញខាត** | | | |
| ចំណូល | 262,892.25 | 230,691.32 | 229,939.07 |
| ចំណេញដុល | 60,702.71 | 47,257.85 | 26,229.12 |
| ចំណេញមុនបង់ពន្ធ | 36,801.61 | 18,454.91 | 3,603.41 |
| ចំណេញសុទ្ធ | 29,145.94 | 14,147.51 | 4,321.00 |
| ចំណេញក្នុងមួយភាគហ៊ុន[៥](រៀល) | 910.81 | 389.08 | 108.02 |
| **របាយការណ៍លំហូរសាច់ប្រាក់** | | | |
| លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ | 4,096.64 | (40,499.66) | (18,592.11) |
| លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ | (1,493.28) | (14,307.54) | (15,939.22) |
| លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន | (4,566.85) | 76,641.50 | 16,200.00 |
| សាច់ប្រាក់សុទ្ធ | (1,963.49) | 21,834.31 | (18,331.32) |
| ▪ **ក្រុមហ៊ុនសវនកម្ម :** | | ប៊ីឌីអូ (ខេមបូឌា) លីមីធីត | |

| ក្រុមប្រឹក្សាភិបាល | មុខតំណែង |
|---|---|
| ១. លោក យ៉ាង សាវស៊ីន | ប្រធានក្រុមប្រឹក្សាភិបាល |
| ២. ឧកញ៉ា លី យុនថៃ | សមាជិកក្រុមប្រឹក្សាភិបាល(អភិបាលឯករាជ្យ) |
| ៣. លោក ឈិន ស៊ុងជី | សមាជិកក្រុមប្រឹក្សាភិបាល(អភិបាលមិនប្រតិបត្តិ) |
| ៤. លោក ឡៅ ឈុងតេ | សមាជិកក្រុមប្រឹក្សាភិបាល(អភិបាលប្រតិបត្តិនិងនាយកប្រតិបត្តិ) |
| ៥. លោកស្រី វ៉ាង យីទីង | សមាជិកក្រុមប្រឹក្សាភិបាល(អភិបាលមិនប្រតិបត្តិ) |



កំពង់ផែស្វយ័តភ្នំពេញ
អាគារលេខ ៦៤៩ ផ្លូវវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក
ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
០២៣ ៤២៧ ៨០២| www.ppap.com.kh

## សេចក្តីសង្ខេបអំពីក្រុមហ៊ុន

បង្កើតឡើងឆ្នាំ៖១៩០៥ ចំនួនបុគ្គលិក៖ ៣២២ នាក់



ឯកឧត្តម ហ៊ី បាវី
ប្រធានអគ្គនាយក

> កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ) គឺប្រតិបត្តិករកំពង់ផែកុងតឺន័រអន្តរជាតិមួយក្នុងចំណោម២នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក.ស.ភ គឺជាប្រតិបត្តិករកំពង់ផែទន្លេធំជាងគេបំផុត និងជាអាជ្ញាធរគ្រប់គ្រងផែនៅក្នុងមណ្ឌលអាជីវកម្មផែ ស្របតាមអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០០៩។ មណ្ឌលអាជីវកម្មផែមានប្រវែង ១៦០គីឡូម៉ែត្រ លាតសន្ធឹងពីខេត្តត្បូងឃ្មុំទៅដល់ព្រំប្រទល់ កម្ពុជា-វៀតណាមនៅឯក្អមសំណា។

> ក.ស.ភ ទទួលសិទ្ធផ្តាច់មុខជាប្រតិបត្តិករកំពង់ផែនៅក្នុងមណ្ឌលអាជីវកម្មផែ ស្របតាមលិខិតជូនដំណឹងលេខ ៦០០ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៥ ដែលចេញពីទីស្តីការគណៈរដ្ឋមន្ត្រី។

> ក.ស.ភ មានចំណតផែចម្បងៗចំនួន៤ នៅក្នុងមណ្ឌលអាជីវកម្មផែ គឺ៖ ទី១ ចំណតផែកុងតឺន័រ LM១៧, ទី២ ចំណតផែពហុបំណង TS៣, ទី៣ ចំណតផែអ្នកដំណើរ និងទេសចរណ៍ TS១, ទី៤ ចំណតផែទន្លេបិទ UM២។

## ព័ត៌មានអំពីអាជីវកម្ម

> ក្នុងរយៈពេល ៤ ឆ្នាំចុងក្រោយ ក.ស.ភ មិនត្រឹមតែបានបង្ហាញពីភាពរីកចម្រើនប៉ុណ្ណោះទេ តែក៏បានបង្ហាញពីភាពរឹងមាំខ្លាំងក្នុងការប្រកបអាជីវកម្មរបស់ខ្លួនផងដែរ។

> ចាប់ពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៥ បរិមាណកុងតឺន័រ បានកើនឡើងទ្វេដងពី ៨១,៦៣១ TEUs ដល់ ១៤៤,៨១៣ TEUs ដែលអត្រាកំណើនជាមធ្យមប្រចាំឆ្នាំ (CAGR) ស្មើនឹង ១៥.៤១%។

> ចំណូលសរុបរបស់ ក.ស.ភ កើនឡើងទ្វេដង ក្នុងរយៈពេល ៤ឆ្នាំចុងក្រោយគិតចាប់ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១៤ ដែលអត្រាកំណើនជាមធ្យមប្រចាំឆ្នាំ ២១,២០% ពី ៦,១៦លានដុល្លារអាមេរិក ដល់ ១៣,២៩លានដុល្លារអាមេរិក។

> កំណើននេះ បានមកពីសេវាកម្មសំខាន់ៗដូចជា សេវាកម្មលើកដាក់ក្រោមដងយោង (Stevedore) សេវាកម្មលើកដាក់នៅលើទីលានកុងតឺន័រ (LOLO) និងសេវាកម្មផែដទៃទៀត ដូចជាសេវាកម្មចូលចតនាវា និងសេវាកម្មកណ្តូធារកិច្ច ដែលមានចំនួនប្រហែល ៩៣.៦៣% នៃចំណូលសរុបរបស់ ក.ស.ភ ក្នុងឆ្នាំ២០១៥។

> គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ក.ស.ភ មានទ្រព្យសកម្មសរុបតម្លៃ ១៥៩.៥៨ លានដុល្លារអាមេរិក (៦៤៧,៩០៩.៤៤លានរៀល) និងមូលធនសរុបចំនួន ១២៦.៤៦លានដុល្លារអាមេរិក (៥១៣,៤០៨.០៧លានរៀល)។

> ដើម្បីឆ្លើយតបនឹងការរីកចម្រើនសេដ្ឋកិច្ចយ៉ាងលឿនរបស់ប្រទេសកម្ពុជា ក.ស.ភ ក៏មានផែនការពង្រីកសមត្ថភាពរបស់ខ្លួនក្នុងការផ្តល់សេវាកម្មលើកដាក់ទំនិញ ការបំពាក់គ្រឿងចក្រលើកដាក់ទំនិញ ទូទៅ ការអភិវឌ្ឍន៍ចំណតផែសម្រាប់ទំនិញចាក់ធារ ការធ្វើទំនើបកម្មចំណតផែអ្នកដំណើរ និងទេសចរណ៍។

## គោលនយោបាយភាគលាភ

ការធានាទិន្នផលភាគលាភអប្បបរមាប្រចាំឆ្នាំដែលស្មើនឹង ៥% នៃថ្លៃ IPO (៥.១២០រៀល) សម្រាប់រយៈពេល ៥ឆ្នាំបន្ទាប់ពីការចុះបញ្ជី មានចំពោះតែមូលបត្រកម្មសិទ្ធិដែលមានសិទ្ធិបោះឆ្នោតប្រភេទ "ក"ប៉ុណ្ណោះ។ ប្រសិន បើភាគលាភជាសាច់ប្រាក់មានទំហំតិចជាងភាគលាភអប្បបរមាដែលបានធានា ក.ស.ភ ត្រូវបែងចែកភាគលាភជាភាគហ៊ុនប្រភេទ "ក" ថ្មីដើម្បីបង្គ្រប់។ ករណីភាគលាភអប្បបរមាដែលបានធានា មិនអាចបង់ពេញនៅក្នុងឆ្នាំសារពើពន្ធមួយក្នុងរយៈពេលធានា ៥ឆ្នាំ នោះភាគលាភដែលមិនបានបង់ នឹងត្រូវបង្គរទៅឆ្នាំសារពើពន្ធបន្ទាប់ទៀត។

ទំហំប្រាក់ចំណេញដែលមានសម្រាប់ការបែងចែកភាគលាភ ត្រូវកំណត់យកតាមគោលការណ៍បែងចែកប្រាក់ចំណេញដូចខាងក្រោម៖

១-ការទូទាត់នូវការខាតបង់កាលពីឆ្នាំសារពើពន្ធមុន

២- ក្រោយពីបានទូទាត់នូវការខាតបង់ឆ្នាំសារពើពន្ធមុនហើយ ប្រសិនបើនៅមានប្រាក់ចំណេញ នោះក្រុមប្រឹក្សាភិបាលអាចប្រើប្រាស់ចំណេញនេះសម្រាប់៖

ក- ផ្តល់ជាប្រាក់បំណាច់ដល់ថ្នាក់ដឹកនាំនិងនិយោជិតតាមលក្ខខណ្ឌដូចខាងក្រោម៖

- ករណីប្រាក់ចំណេញនៅសល់មានចំនួនពី ៥% ទៅ ១០% នៃចំណាយសរុបរបស់ ក.ស.ភ ក្នុងឆ្នាំនោះ ប្រាក់បំណាច់ត្រូវស្មើ ០១ខែនៃប្រាក់បៀវត្សសរុបជាមធ្យមប្រចាំឆ្នាំ
- ករណីប្រាក់ចំណេញនៅសល់មានចំនួនពី ១១% ទៅ ២០% នៃចំណាយសរុបរបស់ ក.ស.ភ ក្នុងឆ្នាំនោះ ប្រាក់បំណាច់ត្រូវស្មើ ០២ខែនៃប្រាក់បៀវត្សសរុបជាមធ្យមប្រចាំឆ្នាំ
- ករណីប្រាក់ចំណេញនៅសល់លើសពី ២០% នៃចំណាយសរុបរបស់ ក.ស.ភ ក្នុងឆ្នាំនោះ ប្រាក់បំណាច់ត្រូវស្មើ ០៣ខែនៃប្រាក់បៀវត្សសរុបជាមធ្យមប្រចាំឆ្នាំ

ខ- ៥% សម្រាប់មូលនិធិបម្រុងតាមច្បាប់ក្រោយពីផ្តល់ជាប្រាក់បំណាច់ដល់ថ្នាក់ដឹកនាំ និងនិយោជិត

គ- ៥% សម្រាប់មូលនិធិបម្រុងសេរីក្រោយពីផ្តល់ជាប្រាក់បំណាច់ដល់ថ្នាក់ដឹកនាំ និងនិយោជិត

ឃ- បង្កើតមូលនិធិអភិវឌ្ឍន៍ ក.ស.ភ។

ចំនួនប្រាក់ចំណេញដែលនៅសល់ក្រោយការបែងចែកខាងលើ ត្រូវបែងចែកជាភាគលាភទៅឲ្យម្ចាស់ភាគហ៊ុន ទៅតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។

| ទិន្នន័យផ្សារ | 2013 | 2014 | 2015 |
|---|---|---|---|
| មូលធនូបនីយកម្មទីផ្សារ(លានរៀល) | - | - | 113,764 |
| ថ្លៃចុងក្រោយ | - | - | 5,500 |
| ថ្លៃខ្ពស់ | - | - | 5,500 |
| ថ្លៃទាប | - | - | 5,140 |
| តម្លៃជួញដូរ/ថ្ងៃ(លានរៀល) | - | - | 45.13 |
| អនុបាតជុំបង្វិល[១] | - | - | 5.59% |
| **ការវាយតម្លៃ** | | | |
| ថ្លៃ/ចំណេញ[២] | - | - | 10.40 |
| ថ្លៃ/តម្លៃក្នុងបញ្ជី[៣] | - | - | 0.82 |
| ទិន្នផលភាគលាភ | - | - | 0.00% |
| អនុបាតភាគលាភបានបង់ | - | - | 0.00% |
| ភាគលាភជាសាច់ប្រាក់ក្នុងមួយភាគហ៊ុន | - | - | 0.00[6] |
| **សូចនាករហិរញ្ញវត្ថុសំខាន់ផ្សេងទៀត** | | | |
| អនុបាតចំណេញធៀបនឹងមូលធន | 0.63% | 1.78% | 2.60% |
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម | 0.48% | 1.38% | 2.05% |
| អនុបាតទ្រព្យសកម្មធៀបនឹងមូលធន | 1.30 | 1.27 | 1.26 |
| អនុបាតចរន្ត | 0.45 | 1.64 | 4.59 |
| **ព័ត៌មានអំពីការលក់ភាគហ៊ុនលើកដំបូង IPO** | | | |
| ថ្លៃ IPO | | | 5,120 |
| តម្លៃចារឹក | | | 4,000 |
| ចំនួនភាគហ៊ុនចុះបញ្ជី | | | 20,684,365 |
| ចំនួនភាគហ៊ុនបោះផ្សាយ | | | 4,136,873 |
| កាលបរិច្ឆេទជួញដូរដំបូង | | | ០៩ ធ្នូ ២០១៥ |
| ថ្លៃបិទដំបូង | | | 5,140 |

- **ក្រុមហ៊ុនធានាទិញមូលបត្រ:** យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី

| ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនចំនួនច្រើន[៤] | % |
|---|---|
| ១. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | 80.00 |
| ២. Mekong Strategic Infrastructure LTD | 5.78 |

| របាយការណ៍ហិរញ្ញវត្ថុ | | | (លានរៀល) |
|---|---|---|---|
| **តារាងតុល្យការ** | **2013** | **2014** | **2015** |
| ទ្រព្យសកម្ម | 613,787.22 | 612,990.29 | 647,909.44 |
| ▪ ទ្រព្យសម្បត្តិ,រោងចក្រនិងបរិក្ខារ | 572,530.99 | 568,417.61 | 568,455.03 |
| ▪ ទ្រព្យសកម្មរយៈពេលខ្លី | 9,634.55 | 12,906.03 | 47,349.35 |
| ▪ សន្និធិ | - | - | - |
| ▪ គណនីត្រូវទទួល | 9,124.45 | 5,553.19 | 11,827.51 |
| ▪ សាច់ប្រាក់ | 510.10 | 7,352.84 | 35,521.84 |
| មូលធនរបស់ភាគហ៊ុនិក | 471,056.15 | 482,408.26 | 513,408.07 |
| ▪ ដើមទុន | 104,237.53 | 108,129.05 | 447,885.45 |
| ▪ ចំណេញរក្សាទុក | 339,604.55 | 345,878.19 | 12,829.70 |
| បំណុល | 142,731.08 | 130,582.04 | 134,501.38 |
| ▪ បំណុលរយៈពេលខ្លី | 21,616.93 | 7,866.44 | 10,316.34 |
| ▪ គណនីត្រូវបង់ | 7,917.13 | 6,574.38 | 7,714.37 |
| **របាយការណ៍ចំណេញខាត** | | | |
| ចំណូល | 45,918.93 | 53,674.13 | 61,458.19 |
| ចំណេញដុល | 27,498.22 | 32,228.07 | 39,580.53 |
| ចំណេញមុនបង់ពន្ធ | 11,536.72 | 16,532.85 | 22,442.37 |
| ចំណេញសុទ្ធ | 2,937.97 | 8,464.07 | 12,943.51 |
| ចំណេញក្នុងមួយភាគហ៊ុន[៥](រៀល) | 177.55 | 511.50 | 770.07 |
| **របាយការណ៍លំហូរសាច់ប្រាក់** | | | |
| លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ | 11,588.18 | 21,652.92 | 19,359.56 |
| លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ | (27,122.37) | (3,587.46) | (6,658.65) |
| លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន | 8,571.23 | 1,601.32 | 15,428.03 |
| សាច់ប្រាក់សុទ្ធ | (6,962.96) | 19,666.77 | 28,128.94 |

- **ក្រុមហ៊ុនសវនកម្ម :** ខេភីអឹមជី ខេមបូឌា ចំកាត់

| ក្រុមប្រឹក្សាភិបាល | មុខតំណែង |
|---|---|
| ១. ឯកឧត្តម ហ៊ី បាវី | ប្រធានអគ្គនាយក |
| ២. ឯកឧត្តម សួន រចនា | សមាជិក (តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន) |
| ៣. ឯកឧត្តម លី ស៊ីវណ្ណា | សមាជិក (តំណាងទីស្តីការគណៈរដ្ឋមន្ត្រី) |
| ៤. ឯកឧត្តម កែន សម្បត្តិ | សមាជិក (តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) |
| ៥. ឯកឧត្តម ប៉ែន សុវិជាតិ | សមាជិក (តំណាងក្រសួងពាណិជ្ជកម្ម) |
| ៦. លោក ហួត ហៃ | សមាជិក (តំណាងសាលារាជធានីភ្នំពេញ) |
| ៧. លោក ព្រុំ សុខានី | សមាជិក (តំណាងនិយោជិតកំពង់ផែស្វយ័តភ្នំពេញ) |



ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី
តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ផ្លូវជាតិលេខ ៤ សង្កាត់កន្ទោក
ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
០២៣ ៧២៩ ៧៩៨ | www.ppsez.com

## សេចក្ដីសង្ខេបអំពីក្រុមហ៊ុន (គិតត្រឹមថ្ងៃទី៣០ មិថុនា ២០១៥) បង្កើតឡើងឆ្នាំ៖២០០៦ ចំនួនបុគ្គលិក៖ ៦៦ នាក់(គិតត្រឹមថ្ងៃទី៣០ មិថុនា ២០១៥)



លោក Hiroshi Uematsu
នាយកប្រតិបត្តិ

នាថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៦ ក្រុមហ៊ុនទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាដើម្បីក្លាយខ្លួនជាអ្នកអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសដែលអាចធ្វើប្រតិបត្តិការអាជីវកម្មច្រើនប្រភេទ ហើយបច្ចុប្បន្ន PPSEZ កំពុងធ្វើប្រតិបត្តិការ និងគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសនៅទីប្រជុំជននៃរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជាដែលមានអាជីវកម្មចម្បងក្នុងការអភិវឌ្ឍដីឧស្សាហកម្មសម្រាប់លក់ និង/ឬ ជួល។ បន្ថែមពីលើនេះ ក្នុងនាមជាប្រតិបត្តិករ ក្រុមហ៊ុនក៏មានផ្ដត់ផ្គង់សេវាកម្មដែលពាក់ព័ន្ធ ព្រមជាមួយបរិក្ខារចាំបាច់នានា នៅក្នុងបរិវេណ PPSEZ ដែលរួមមាន ប្រព្រឹត្តកម្មទឹកសំណល់ ការផ្គត់ផ្គង់ និងចែកចាយទឹកស្អាត សេវាជួល ការថែទាំប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ សេវាផ្ដល់ប្រឹក្សាយោបល់ និងជំនួយកិច្ចការរដ្ឋបាល សេវាសន្តិសុខ ការផលិត និងចែកចាយថាមពលអគ្គីសនី ព្រមទាំងសេវាផែស្ងួត ជូនដល់អ្នកដែលបានជួល និងវិនិយោគិនតំបន់ដទៃទៀតក្នុង PPSEZ។

PPSEZ រក្សាបាននូវចំនួនវិនិយោគិនតំបន់ច្រើនជាងគេក្នុងចំណោមតំបន់សេដ្ឋកិច្ចពិសេសទាំង ៣៤ ហើយជាតំបន់សេដ្ឋកិច្ចពិសេសធំមួយ បើគិតតាមទំហំផ្ទៃដីរបស់ PPSEZ ដែលមានប្រមាណ ៣៥៧.៣២ហិចតា។

## ព័ត៌មានអំពីអាជីវកម្ម

> ក្រោយការបង្កើតឡើងនៅឆ្នាំ ២០០៦ ក្រុមហ៊ុនបានទិញដីទំហំប្រមាណ ៣៥២.៤៦ហិចតា ក្នុងនោះដីទំហំ ១៣៧.៩៤ហិចតា ត្រូវបានប្រើប្រាស់ក្នុងការសាងសង់សំណង់ហេដ្ឋារចនាសម្ព័ន្ធធំៗ ក្នុងដំណាក់កាលទី១ ជាមួយនឹង ដីឡូត៍សំរាប់រោងចក្រ និងដីឡូត៍សំរាប់ពាណិជ្ជកម្មសរុបចំនួន ៧៨ កន្លែង។

> ក្នុងឆ្នាំ ២០១០ ក្រុមហ៊ុនយើងទទួលបានវិញ្ញាបនបត្របញ្ជាក់បទដ្ឋានអន្តរជាតិ ISO:៩០០១ សម្រាប់ការប្ដេជ្ញាក្នុងការគ្រប់គ្រងប្រកបដោយគុណភាព និង ISO: ១៤០០១ សម្រាប់ការត្រួតពិនិត្យបរិស្ថាន។

> នាឆ្នាំ ២០១១ ក្នុងដំណាក់កាលទី២ ក្រុមហ៊ុនបានសាងសង់ទីតាំងសម្រាប់រោងចក្រ និង ហេដ្ឋារចនាសម្ព័ន្ធបន្ថែមទៀត សម្រាប់ធានាដល់ វិនិយោគិនថ្មី។

> ក្នុងឆ្នាំ ២០១៤ ក្រុមហ៊ុនបានទិញដីទំនេរទំហំប្រមាណ ៥២.៩៥ ហិចតាបន្ថែមទៀតដែលមានទីតាំងនៅក្នុងខេត្តបន្ទាយមានជ័យ ដើម្បីប្រែក្លាយ ទៅជាតំបន់សេដ្ឋកិច្ចពិសេស។

> PPSEZ មានវិនិយោគិនចម្រុះជាតិសាសន៍ចំនួន ៧៧ ដែលវិនិយោគិនភាគច្រើនមកពីប្រទេសជប៉ុន ម៉ាឡេស៊ី តៃវ៉ាន់ ចិន សហរដ្ឋអាមេរិក និង កូរ៉េ ដែលវិនិយោគលើឧស្សាហកម្មផ្សេងៗគ្នា ដូចជា គ្រឿងបន្លាស់យានយន្ត កាត់ដេរ អាហារនិងភេសជ្ជៈ ជាដើម។

> ដើម្បីបន្តជាតំបន់សេដ្ឋកិច្ចពិសេសដែលឈានមុខគេនៅកម្ពុជា ក្រុមហ៊ុនបានរៀបចំផែនការអនាគតដូចខាងក្រោម៖

១. បន្តទិញដីនៅតំបន់ជុំវិញ PPSEZ

២. បន្តការធ្វើឱ្យមានភាពចម្រុះគ្នានៃវិនិយោគិនក្នុងតំបន់ ដោយផ្ដោតសំខាន់លើវិនិយោគិនដែលអនុវត្តដំណើរការផលិតមានលក្ខណៈពេញលេញ និងផ្នែកផ្សេងៗទៀតនៃខ្សែសង្វាក់តម្លៃនៃសកម្មភាពផលិត និងដំឡើង

៣. ពង្រីកខ្លួនទៅកាន់ផ្នែកដទៃទៀតនៃកម្ពុជា និងបណ្ដាប្រទេសក្នុងតំបន់មេគង្គ

៤. ពង្រីកការផ្ដល់សេវាកម្មដែលពាក់ព័ន្ធ ពិសេសសមត្ថភាពក្នុងការផ្គត់ផ្គង់ទឹកនៅក្នុង PPSEZ។

## គោលនយោបាយភាគលាភ

ក្រុមប្រឹក្សាភិបាលបានអនុម័តគោលនយោបាយបម្រុងទុកប្រាក់ចំណេញ (profit plough back policy) សម្រាប់ឆ្នាំសារពើពន្ធ ២០១៥ និង រយៈពេលបន្តទៅមុខទៀត ដោយផ្អែកទៅលើ លទ្ធភាពក្នុងការបង់ភាគលាភ ឬការបង់ចំណែកដែលមានទម្រង់ផ្សេងទៀតដល់ភាគហ៊ុនិក អាស្រ័យលើកត្តាមួយចំនួន ដែលរួមមានជាអាទិ៍ដូចជា៖

(i) ស្ថានភាពហិរញ្ញវត្ថុដែលរួមមានស្ថានភាពលំហូរសាច់ប្រាក់ និងសន្ទនីយភាព អត្រាផលធៀបដើមទុននិងឥណទាន (gearing) និងអតិរេក (surplus) របស់ក្រុមហ៊ុន

(ii) ស្ថានភាពហិរញ្ញវត្ថុដែលបានរំពឹងទុក រួមទាំងលទ្ធភាពរកចំណេញរបស់ក្រុមហ៊ុន

(iii) ទុនបង្វិលដែលអាចប្រើប្រាស់បានដែលរួមមាន ទុនដែលត្រូវបែកចែកសម្រាប់ចំណាយមូលធន និងគម្រោងវិនិយោគពេលអនាគតរបស់ក្រុមហ៊ុន និង

(iv) កាតព្វកិច្ចបំណុលដែលមាននាពេលបច្ចុប្បន្ន និងអនាគត ព្រមទាំងចំណាយការប្រាក់របស់ក្រុមហ៊ុន។

ដូចដែលបានកំណត់ក្នុងចំណុច (i) ដល់ (iv) ខាងលើ ក្រុមហ៊ុនមានគោលដៅកំណត់អនុបាតភាគលាភបានបង់មិនឲ្យតិចជាង ២០% នៃប្រាក់ចំណេញរបស់ក្រុមហ៊ុន ដល់អ្នកកាន់កាប់មូលបត្រទាំងឡាយ អនុលោមតាម CIFRS ។

វិនិយោគិនគួរកត់សម្គាល់ថា គោលនយោបាយបែងចែកភាគលាភគ្រាន់តែបង្ហាញអំពីគោលបំណងបច្ចុប្បន្នរបស់ក្រុមហ៊ុនប៉ុណ្ណោះ ហើយវាមិនត្រូវបានចាត់ទុកថាជាសេចក្ដីថ្លែងចងកាតព្វកិច្ចតាមផ្លូវច្បាប់ណាមួយឡើយពាក់ព័ន្ធនឹងការបែងចែកភាគលាភនាពេលអនាគតឡើយ។ គោលនយោបាយនេះអាចត្រូវបានកែប្រែ (ដែលរួមមានការមិនប្រកាសផ្សេងទៀតដែលពាក់ព័ន្ធ) ដោយឆន្ទានុសិទ្ធិរបស់ក្រុមប្រឹក្សាភិបាល។

| ទិន្នន័យជួញដូរ | 2013 | 2014 | 2015 |
|---|---|---|---|
| មូលធនូបនីយកម្មទីផ្សារ( លានរៀល ) | - | - | - |
| ថ្លៃចុងក្រោយ | - | - | - |
| ថ្លៃខ្ពស់ | - | - | - |
| ថ្លៃទាប | - | - | - |
| តម្លៃជួញដូរ/ថ្ងៃ( លានរៀល ) | - | - | - |
| អនុបាតជុំបង្វិល[១] | - | - | - |
| **ការវាយតម្លៃ** | | | |
| ថ្លៃ/ចំណេញ[២] | - | - | - |
| ថ្លៃ/តម្លៃក្នុងបញ្ជី[៣] | - | - | - |
| ទិន្នផលភាគលាភ | - | - | - |
| អនុបាតភាគលាភបានបង់ | - | - | - |
| ភាគលាភជាសាច់ប្រាក់ក្នុងមួយភាគហ៊ុន | - | - | - |
| **សូចនាករហិរញ្ញវត្ថុសំខាន់ផ្សេងទៀត** | | | |
| អនុបាតចំណេញធៀបនឹងមូលធន | 29.38% | 29.30% | 16.88% |
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម | 11.01% | 12.39% | 8.76% |
| អនុបាតទ្រព្យសកម្មធៀបនឹងមូលធន | 2.71 | 2.11 | 1.77 |
| អនុបាតចរន្ត | 1.99 | 2.18 | 2.98 |
| **ព័ត៌មានអំពីការលក់ភាគហ៊ុនលើកដំបូង IPO** | | | |
| ថ្លៃ IPO | | | 2,860 |
| តម្លៃចារឹក | | | 2,000 |
| ចំនួនភាគហ៊ុនចុះបញ្ជី | | | 57,875,000 |
| ចំនួនភាគហ៊ុនបោះផ្សាយ | | | 11,575,000 |
| កាលបរិច្ឆេទជួញដូរដំបូង | | | ៣០ ឧសភា ២០១៦ |
| ថ្លៃបិទដំបូង | | | 2,890 |

- **សហក្រុមហ៊ុនធានាទិញមូលបត្រ:**
  អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យួរីធី
  កម្ពុ ស៊ីឃ្យួរីធី ភីអិលស៊ី
  កាណា ស៊ីឃ្យួរីធី អិលធីឌី

| ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនចំនួនច្រើន[៤] | មុន IPO % | ក្រោយ IPO % |
|---|---|---|
| ១. លោកជំទាវឧកញ៉ា លីម ឈីវហួរ | 70.00 | 56.00 |
| ២. ZEPHYR CO., LTD | 22.00 | 17.60 |

| របាយការណ៍ហិរញ្ញវត្ថុ<br>តារាងតុល្យការ | 2013 | 2014 | ( លានរៀល )<br>2015<br>គ្មានសវនកម្ម |
|---|---|---|---|
| ទ្រព្យសកម្ម | 187,017.49 | 199,485.90 | 196,694.13 |
| ▪ ទ្រព្យសម្បត្តិ,រោងចក្រនិងបរិក្ខារ | 39,891.93 | 57,361.01 | 57,146.11 |
| ▪ ទ្រព្យសកម្មរយៈពេលខ្លី | 112,034.17 | 94,176.71 | 92,693.56 |
| ▪ សន្និធិ | 72,023.53 | 44,615.47 | 53,554.65 |
| ▪ គណនីត្រូវទទួល | 30,755.53 | 48,776.58 | 34,417.80 |
| ▪ សាច់ប្រាក់ | 9,255.12 | 784.66 | 4,721.10 |
| មូលធនរបស់ភាគហ៊ុនិក | 69,065.07 | 94,397.98 | 111,167.09 |
| ▪ ដើមទុន | 3,995.00 | 4,075.00 | 93,757.50 |
| ▪ ចំណេញរក្សាទុក | 65,070.07 | 90,322.98 | 17,409.59 |
| បំណុល | 117,952.42 | 105,087.92 | 85,527.04 |
| ▪ បំណុលរយៈពេលខ្លី | 56,404.77 | 43,293.06 | 31,091.79 |
| ▪ គណនីត្រូវបង់ | 22,847.64 | 9,812.77 | 8,535.76 |
| **របាយការណ៍ចំណេញខាត** | | | |
| ចំណូល | 66,780.66 | 95,159.06 | 66,665.99 |
| ចំណេញដុល | 32,888.71 | 50,979.79 | 42,557.86 |
| ចំណេញមុនបង់ពន្ធ | 20,873.06 | 34,752.06 | 25,589.94 |
| ចំណេញសុទ្ធ | 17,691.58 | 23,949.88 | 17,348.23 |
| ចំណេញក្នុងមួយភាគហ៊ុន[៥]( រៀល ) | 382.11 | 517.28 | 374.69 |
| **របាយការណ៍លំហូរសាច់ប្រាក់** | | | |
| លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ | (1,394.01) | 8,580.58 | 24,771.27 |
| លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ | (16,801.28) | (18,484.19) | (6,016.10) |
| លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន | 33,017.46 | 1,247.81 | (14,813.92) |
| សាច់ប្រាក់សុទ្ធ | 14,822.16 | (8,655.79) | 3,941.25 |
| ▪ **ក្រុមហ៊ុនសវនកម្ម :** | | | ប៊ីឌីអូ ( ខេមបូឌា ) លីមីធីត |

| ក្រុមប្រឹក្សាភិបាល | មុខតំណែង |
|---|---|
| ១. លោកជំទាវឧកញ៉ា លីម ឈីវហួរ | ប្រធានក្រុមប្រឹក្សាភិបាលមិនប្រតិបត្តិ |
| ២. លោក Hiroshi Uematsu | អភិបាលប្រតិបត្តិ |
| ៣. លោក តាន់ កាក់ឃុន | អភិបាលមិនប្រតិបត្តិ |
| ៤. លោកស្រី តាន់ សឺយមួយ | អភិបាលមិនប្រតិបត្តិ |
| ៥. លោក Hiroshi Otsubo | អភិបាលមិនប្រតិបត្តិ |
| ៦. លោក Kenji Toyota | អភិបាលមិនប្រតិបត្តិ |
| ៧. លោក Kang Wei Geih | អភិបាលឯករាជ្យ |
| ៨. លោក ហែម សុវត្ថិ | អភិបាលឯករាជ្យ |

# សមាជិករបស់ ផ.ម.ក.

| ល.រ | នាមករណ៍ក្រុមហ៊ុន | | អាសយដ្ឋានទំនាក់ទំនង |
|---|---|---|---|
| ១ | អេស៊ីលីដា ស៊ីឃ្យួរីធី ភីអិលស៊ី | អាសយដ្ឋាន<br>ទូរសព្ទ<br>ទូរសារ<br>គេហទំព័រ | : ជាន់ទី ៥ អគារធនាគារ អេស៊ីលីដា ភីអិលស៊ី ការិយាល័យកណ្តាលអគារ លេខ ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>: ០២៣ ៩៩៩ ៩៦៦ / ០២៣ ៧២៣ ៣៨៨ / ០២៣ ៩៩៩ ៩៧៧<br>: ០២៣ ៧២៣ ៣៧៧<br>: www.acledasecurities.com.kh |
| ២ | ខេប ស៊ីឃ្យូរីធី លីមីធីត | អាសយដ្ឋាន<br>ទូរសព្ទ<br>ទូរសារ | : អាគារលេខ៩២D ក្រុម ៦៧ ផ្លូវ ២៨៩ សង្កាត់បឹងកក់ ២ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ<br>: ០២៣ ៦៩៩ ៤០០០ / ០២៣ ៤៥៥ ៩៥៨៨<br>: ០២៣ ៤២៦ ៦២៨ |
| ៣ | ខេមបូឌា - វៀតណាម ស៊ីឃ្យួរីធី ភីអិលស៊ី | អាសយដ្ឋាន<br>ទូរសព្ទ<br>គេហទំព័រ | : អគារលេខ ៣៧០ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ<br>: ០២៣ ៧២៣ ៨៩៩ ទូរសារ: ០២៣ ៧២៣ ៨៩០<br>: www.cvs.com.kh |
| ៤ | កម្ពុ ស៊ីឃ្យួរីធី ភីអិលស៊ី | អាសយដ្ឋាន<br>ទូរសព្ទ<br>គេហទំព័រ | : អគារកម្ពុប៊ែង ជាន់ទី6 លេខ២៣ ផ្លូវក្រុមួនស (ផ្លូវ១១៤) សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>: ០២៣ ៩៩៩ ៨៨០ ទូរសារ: ០២៣ ៩៩៩ ៨៨៣<br>: campusecurities.com.kh |
| ៥ | កាណា ស៊ីឃ្យូរីធី អិលធីឌី | អាសយដ្ឋាន<br>ទូរសព្ទ<br>គេហទំព័រ | : វិមានកាណាឌីយ៉ា ជាន់ទី១៥ អគារលេខ៣១៥ ផ្លូវព្រះអង្គឌួង (កែងមហាវិថីព្រះមុនីវង្ស) សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>: ០២៣ ៩៩៩ ៨៨៧ ទូរសារ: ០២៣ ៩៩៩ ៨៨៣<br>: www.canasecurities.com.kh |
| ៦ | ហ្គោលដេន ហ្វ័រឈូន (ខេមបូឌា) ស៊ីឃ្យូរីធី ភីអិលស៊ី | អាសយដ្ឋាន<br>ទូរសព្ទ<br>គេហទំព័រ | : ១៧៤ABCD, មហាវិថីម៉ៅសេទុង, សង្កាត់ទំនុបទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ(អតីតអាគារ Ming Wouy)<br>: ០២៣ ២១៨ ២២៨ / ០២៣ ២១៨ ៣៨៨ ទូរសារ: ០២៣ ២១០ ១១១<br>: www.goldenfortune.com.kh |
| ៧ | ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី | អាសយដ្ឋាន<br>ទូរសព្ទ<br>គេហទំព័រ | : អគារលេខ ៣២ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>: ០២៣ ៤២៦ ៩៩៩ ទូរសារ: ០២៣ ៤២៦ ៤៩៥<br>: www.pps.com.kh |
| ៨ | អ អេច ប៊ី អ្វ អេស ខេ ឥណ្ឌូឆៃណា ស៊ីឃ្យួរីធី លីមីធីត | អាសយដ្ឋាន<br>ទូរសព្ទ<br>គេហទំព័រ | : អគារ ១-៣ ជាន់ទី ២-៣ ផ្លូវលេខ ២៧១ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ<br>: ០២៣ ៩៦៩ ១៦១ ទូរសារ: ០២៣ ៩៦៩ ១៧១<br>: www.rhbgroup.com |
| ៩ | អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី | អាសយដ្ឋាន<br>ទូរសព្ទ<br>គេហទំព័រ | : ជាន់ទី១៣ វិមានភ្នំពេញ អគារលេខ៤៤៥ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ<br>: ០២៣ ៩៩៩ ៥៩៥ ទូរសារ: ០២៣ ៩៩៦ ៩៧៣<br>: www.sbiroyal.com |
| ១០ | យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី | អាសយដ្ឋាន<br>ទូរសព្ទ<br>ទូរសារ<br>គេហទំព័រ | : អគារ Emerald លេខ ៤៤៥ ជាន់ទី៤ មហាវិថីព្រះនរោត្តម សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>: ០២៣ ៨៦០ ៨០០ / ០៩២ ៧៧៧ ៣០៩<br>: ០២៣ ២២៤ ១២៦<br>: www.yuantacambodia.com |

### កំណត់សម្គាល់៖

១. អនុបាតជុំបង្វិល = បរិមាណជួញដូរសរុបក្នុងមួយឆ្នាំ/ចំនួនភាគហ៊ុនអណ្តែត

* ចំនួនភាគហ៊ុនអណ្តែត = ចំនួនភាគហ៊ុនចុះបញ្ជី – ភាគហ៊ុនរបស់ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនចំនួនច្រើន (៤) – ភាគហ៊ុនិកយុទ្ធសាស្ត្រ – ភាគហ៊ុនលៃបម្រុងទុកសម្រាប់មន្ត្រីនិយោជិត (ESOP)
* ភាគហ៊ុនិកយុទ្ធសាស្ត្រ សំដៅដល់ភាគហ៊ុនិកដែលជាអភិបាល បុគ្គលិកជាន់ខ្ពស់នៃបុគ្គលចុះបញ្ជីលក់មូលបត្រ និងសមាជិកគ្រួសារផ្ទាល់របស់បុគ្គលទាំងនោះ។

២. ថ្លៃ/ចំណេញ = មធ្យមនៃថ្លៃជួញដូរខ្ពស់បំផុតនិងទាបបំផុតក្នុងឆ្នាំ/ចំណេញក្នុងមួយភាគហ៊ុនក្នុងឆ្នាំមុន

៣. ថ្លៃ/តម្លៃក្នុងបញ្ជី = ថ្លៃចុងក្រោយ/តម្លៃក្នុងបញ្ជីក្នុងមួយភាគហ៊ុន

* តម្លៃក្នុងបញ្ជីរបស់ PWSA មិនរាប់បញ្ចូលភាគហ៊ុនប្រភេទ ក ដែលមានចំនួន ៣៩១.១០០.៩៤២ និងមានតម្លៃចារឹក ១.០០០រៀល
* តម្លៃក្នុងបញ្ជីរបស់ PPAP មិនរាប់បញ្ចូលភាគហ៊ុនប្រភេទ គ ដែលមានចំនួន ៩៣.៧៦៩.១២០ និងមានតម្លៃចារឹក ៤.០០០រៀល

៤. ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនចំនួនច្រើន ៖ ភាគហ៊ុនិកកាន់កាប់ភាគហ៊ុន ≥៥% នៃភាគហ៊ុនចុះបញ្ជី

៥. ចំណេញក្នុងមួយភាគហ៊ុនមុនឆ្នាំធ្វើ IPO = ចំណេញសុទ្ធ/ចំនួនភាគហ៊ុនសរុបមុនពេលធ្វើ IPO

ចំណេញក្នុងមួយភាគហ៊ុននៅឆ្នាំធ្វើ IPO = ចំណេញសុទ្ធ/មធ្យមទម្ងន់នៃចំនួនភាគហ៊ុនសរុបក្នុងឆ្នាំធ្វើ IPO ផ្អែកលើថ្ងៃចុះបញ្ជីលក់ភាគហ៊ុនដំបូង

៦. ភាគលាភជាសាច់ប្រាក់ក្នុងមួយភាគហ៊ុនរបស់ PPAP ក្នុងឆ្នាំ២០១៥ = 0 (យោងតាមសេចក្តីជូនដំណឹងស្តីពីការបែងចែកភាគលាភសម្រាប់ឆ្នាំ២០១៥ របស់ ក.ស.ភ. ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ក.ស.ភ. បានសម្រេចបែងចែកភាគលាភជាសាច់ប្រាក់ចំនួន ២៥,៦០រៀលក្នុងមួយភាគហ៊ុនសម្រាប់ឆ្នាំ២០១៥ ប៉ុន្តែសម្រេចបង្គរភាគលាភនេះ ដោយទុកបូកជាមួយភាគលាភអប្បបរមា ៥%ក្នុងមួយឆ្នាំដែលបានធានាសម្រាប់ឆ្នាំ ២០១៦)

## សេចក្តីប្រកាស

ការផ្តល់ជូនទិន្នន័យនិងព័ត៌មាននៅក្នុងប័ណ្ណព័ត៌មាននេះ គឺក្នុងគោលបំណងដើម្បីពង្រីកវិសាលភាពនៃការទទួលបានព័ត៌មានសម្រាប់ការវិនិយោគតែប៉ុណ្ណោះ។ ផ.ម.ក. បានខិតខំប្រឹងប្រែងក្នុងការធានាពីភាពត្រឹមត្រូវនៃទិន្នន័យនិងព័ត៌មានទាំងនេះប៉ុន្តែមិនទទួលខុសត្រូវ លើការខាតបង់ណាមួយដែលកើតឡើងបណ្តាលមកពីការប្រើប្រាស់ទិន្នន័យ និងព័ត៌មានដែលផ្តល់ជូននៅក្នុងប័ណ្ណព័ត៌មាននេះឡើយ។

ផ្សារមូលបត្រកម្ពុជា

CSX


ក្រុមហ៊ុន ផ្សារមូលបត្រកម្ពុជា

អគារ ផ.ម.ក. វិថីព្រះមហាក្សត្រីយានី កុសុមៈ (ផ្លូវ ១០៦) សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរសព្ទ: (៨៥៥) ២៣ ៩៥ ៨៨ ៨៨ / ២៣ ៩៥ ៨៨ ៨៥

ទូរសារ: (៨៥៥) ២៣ ៩៩ ៥៥ ៥៨

គេហទំព័រ: www.csx.com.kh

Facebook: Cambodia Securities Exchange